# គណបក្ស ភ្លើងទៀន
# CANDLELIGHT PARTY
**សីលធម៌ សច្ចធម៌ យុត្តិធម៌**

## កិច្ចខិតខំប្រឹងប្រែងរបស់គណបក្ស ភ្លើងទៀន
## ក្នុងការរកដំណោះស្រាយពាក់ព័ន្ធប្រកាសលេខ ១៩៣ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨
## របស់ក្រសួងមហាផ្ទៃ ដើម្បីបានចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
## នីតិកាលទី៧ ឆ្នាំ២០២៣

**គណបក្ស ភ្លើងទៀន** បដិសេធដាច់អហង្ការ ចំពោះការចោទប្រកាន់ថា គណបក្ស ភ្លើងទៀន បានលាក់ច្បាប់ដើមនៃប្រកាសលេខ ១៩៣ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ ដោយមានចេតនាមិនចង់ចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលជាឧបាយកលធ្វើឲ្យបរទេសដាក់សម្ពាធលើរាជរដ្ឋាភិបាលកម្ពុជា និងបង្កចលាចលក្នុងសង្គម។

**គណបក្ស ភ្លើងទៀន** បានបញ្ជាក់ជំហររបស់ខ្លួន ជាច្រើនលើករួចមកហើយ អំពីឆន្ទៈពិតប្រាកដ និងយ៉ាងមោះមុត ក្នុងការចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ហើយបានខិតខំប្រឹងប្រែងអស់ពីលទ្ធភាពក្នុងការធ្វើទំនាក់ទំនងជាមួយស្ថាប័នមានសមត្ថកិច្ចនានា ពិសេសក្រសួងមហាផ្ទៃ ដើម្បីរកដំណោះស្រាយពាក់ព័ន្ធប្រកាសលេខ ១៩៣ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃ និងបញ្ជាក់អំពីភាពស្របច្បាប់របស់គណបក្ស ភ្លើងទៀន ដែលក្រសួងមហាផ្ទៃបានទទួលស្គាល់តាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ។

**គណបក្ស ភ្លើងទៀន** បានបាត់ច្បាប់ដើមនៃប្រកាសលេខ ១៩៣ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ ក្នុងអំឡុងឆ្នាំ២០១៧ នៅពេលដែលទីស្នាក់ការកណ្តាលគណបក្ស ភ្លើងទៀន ដែលស្ថិតនៅខាងក្រោមទីស្នាក់ការអតីតគណបក្សសង្គ្រោះជាតិ ត្រូវបានបិទដោយអំណាចសាលដីការបស់តុលាការកំពូល ហើយនៅពេលនោះ គណបក្ស ភ្លើងទៀន បានដាក់លិខិតស្នើសុំទៅសាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ ដើម្បីប្រើប្រាស់ទីស្នាក់ការ និងប្រមូលឯកសារនានារបស់គណបក្សពីទីស្នាក់ការ ប៉ុន្តែមិនបានទទួលការអនុញ្ញាតពីសាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ឡើយ ជាហេតុធ្វើឲ្យឯកសារមួយចំនួនរបស់គណបក្ស រួមទាំងច្បាប់ដើមនៃប្រកាសលេខ ១៩៣ ប្រក ផង ត្រូវបានបាត់បង់។



ផ្ទះលេខ ៣២០ ផ្លូវលេខ ១០ម៉ែត្រថ្មី បុរីពិភពថ្មី ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
#320, Street 10m Thmey, Borey Piphob Thmey, Bayarb Village, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh
Website: www.candlelightparty.org / Email: info@candlelightparty.org

ខាងក្រោមនេះ គឺជាកិច្ចខិតខំប្រឹងប្រែងរបស់គណបក្ស ភ្លើងទៀន ក្នុងការរកដំណោះស្រាយពាក់ព័ន្ធប្រកាសលេខ ១៩៣ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃ ដើម្បីគណបក្ស ភ្លើងទៀន យកមកប្រើប្រាស់សម្រាប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣៖

១-នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ គណបក្ស ភ្លើងទៀន បានធ្វើលិខិតទៅក្រសួងមហាផ្ទៃ ដើម្បីធ្វើសំណើសុំច្បាប់ដើម ឬសេចក្តីចម្លង ដែលមានបញ្ជាក់នីត្យានុកូលកម្ម នៃប្រកាសលេខ ១៩៣ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ ដើម្បីគណបក្ស ភ្លើងទៀន យកមកប្រើប្រាស់ជាផ្លូវការ សម្រាប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ។

២-នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ តំណាងគណបក្ស ភ្លើងទៀន បានជួបប្រជុំជាមួយតំណាងក្រសួងមហាផ្ទៃ លើកទី១ ដើម្បីពិភាក្សាអំពីសំណើសុំច្បាប់ដើម ឬសេចក្តីចម្លង ដែលមានបញ្ជាក់នីត្យានុកូលកម្ម នៃប្រកាសលេខ ១៩៣ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃ តាមលិខិតស្នើសុំរបស់គណបក្ស ភ្លើងទៀន ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣។ ជាលទ្ធផលនៃកិច្ចប្រជុំ តំណាងក្រសួងមហាផ្ទៃ បានស្នើឲ្យគណបក្ស ភ្លើងទៀន ដាក់ពាក្យបណ្តឹងទៅនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ ដើម្បីធ្វើការស្រាវជ្រាវ និងមានកំណត់ហេតុច្បាស់លាស់ ហើយត្រូវរៀបចំសំណើដាក់ជូនក្រសួងមហាផ្ទៃឡើងវិញ។

៣-នៅថ្ងៃទី២៥ និង ២៦ ខែមេសា ឆ្នាំ២០២៣ គណបក្ស ភ្លើងទៀន បានអនុវត្តតាមសំណើរបស់ក្រសួងមហាផ្ទៃ ដោយបានដាក់ពាក្យបណ្តឹងចំនួនពីរលើក ទៅនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ និងនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ស្តីពីការបាត់ច្បាប់ដើមនៃប្រកាសលេខ ១៩៣ ប្រក ប៉ុន្តែត្រូវបាននគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ចាក់អង្រែលើ និងសង្កាត់ទន្លេបាសាក់ បដិសេធមិនព្រមទទួលយកពាក្យបណ្តឹងរបស់គណបក្ស ភ្លើងទៀន ដោយអះអាងថាថ្នាក់លើមិនឲ្យទទួលពាក្យបណ្តឹងរបស់គណបក្ស ភ្លើងទៀន ឡើយ។

៤-នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ គណបក្ស ភ្លើងទៀន បានដាក់លិខិតជាលើកទី២ ទៅក្រសួងមហាផ្ទៃ ស្នើសុំក្រសួងមហាផ្ទៃ ផ្តល់ជូនគណបក្ស ភ្លើងទៀន នូវច្បាប់ទុតិយតា ឬសេចក្តីចម្លងដែលមានបញ្ជាក់នីត្យានុកូលកម្ម នៃប្រកាសលេខ ១៩៣ ប្រក។

៥-នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ គណបក្ស ភ្លើងទៀន បានធ្វើលិខិតទៅក្រសួងមហាផ្ទៃ ដើម្បីសុំជួប**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ឬ **តំណាងក្រសួងមហាផ្ទៃ** ដើម្បីពិភាក្សាអំពីសំណើរបស់គណបក្ស ភ្លើងទៀន សុំច្បាប់ទុតិយតា ឬសេចក្តីចម្លងដែលមានបញ្ជាក់នីត្យានុកូលកម្ម នៃប្រកាសលេខ ១៩៣ ប្រក។

៦-នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ ថ្នាក់ដឹកនាំគណបក្ស ភ្លើងទៀន បានជួបជាមួយតំណាងជាន់ខ្ពស់ក្រសួងមហាផ្ទៃ លើកទី២ ដឹកនាំដោយ **ឯកឧត្តម ម៉ុន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដើម្បីពិភាក្សាអំពីសំណើរបស់គណបក្ស ភ្លើងទៀន សុំច្បាប់ទុតិយតា ឬសេចក្តីចម្លង ដែលមានបញ្ជាក់នីត្យានុកូលកម្ម នៃប្រកាសលេខ ១៩៣ ប្រក។ ជាលទ្ធផល ក្រសួងមហាផ្ទៃបានចេញលិខិតបញ្ជាក់លេខ ០៤៣ប ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ ដែលបញ្ជាក់ថា គណបក្ស ភ្លើងទៀន បានចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ដែលមានលោក **ទាវ វណ្ណុល** ជាប្រធានគណបក្ស និងមានអាសយដ្ឋានទីស្នាក់ការកណ្តាលបច្ចុប្បន្នផ្ទះលេខ៣២០អឺសេរ៉ូ ផ្លូវ១០ ម៉ែត្រថ្មី (បុរីពិភពថ្មី) ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

៧-នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៣ គណបក្ស ភ្លើងទៀន បានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលមាន ២៥ (ម្ភៃប្រាំ) មណ្ឌលរាជធានី ខេត្ត នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដោយជូនភ្ជាប់នូវឯកសារលិខិតបញ្ជាក់លេខ ០៤៣ ប ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ដែលបញ្ជាក់ថា គណបក្ស ភ្លើងទៀន បានចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ។

៨-នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ ថ្នាក់ដឹកនាំគណបក្ស ភ្លើងទៀន បានជួបជាមួយតំណាង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីពិភាក្សាអំពីឯកសារបំពេញបន្ថែមចំណុចខ្វះខាតរបស់គណបក្ស ភ្លើងទៀន ដែលត្រូវភ្ជាប់ជាមួយពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ពិសេសប្រកាសលេខ ១៩៣ ប្រក ដែលមានបញ្ជាក់នីត្យានុកូលកម្ម។

៩-នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ គណបក្ស ភ្លើងទៀន បានផ្ញើលិខិតទៅក្រសួងមហាផ្ទៃ ដើម្បីសុំជួប **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ឬ **តំណាងជាន់ខ្ពស់ក្រសួងមហាផ្ទៃ** ដើម្បីសុំក្រសួងមហាផ្ទៃ ជួយផ្តល់ដំណោះស្រាយពាក់ព័ន្ធប្រកាសលេខ ១៩៣ ប្រក សម្រាប់គណបក្ស ភ្លើងទៀន យកមកប្រើប្រាស់ក្នុងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

១០-នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ ថ្នាក់ដឹកនាំគណបក្ស ភ្លើងទៀន បានជួបជាមួយតំណាងជាន់ខ្ពស់ក្រសួងមហាផ្ទៃ លើកទី៣ ដឹកនាំដោយឯកឧត្តម **ម៉ុន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដើម្បីពិភាក្សាអំពីដំណោះស្រាយពាក់ព័ន្ធប្រកាសលេខ ១៩៣ ប្រក ដោយគណបក្ស ភ្លើងទៀន ទទូចស្នើសុំឲ្យក្រសួងមហាផ្ទៃ ផ្តល់ជូននូវច្បាប់ទុតិយតា ឬសេចក្តីចម្លងមានបញ្ជាក់នីត្យានុកូលកម្ម ឬបញ្ជាក់តល់បញ្ជីនៅក្រសួងមហាផ្ទៃ នៃប្រកាសលេខ ១៩៣ ប្រក ដើម្បីគណបក្ស ភ្លើងទៀន យកមកប្រើប្រាស់ជាផ្លូវការ សម្រាប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាល

ទី៧ ឆ្នាំ២០២៣។ ជាលទ្ធផលនៃជំនួប តំណាងក្រសួងមហាផ្ទៃ ពុំបានធ្វើតាមសំណូមពររបស់គណបក្ស ភ្លើងទៀន ឡើយ ដោយតំណាងក្រសួងមហាផ្ទៃ បានបញ្ជាក់ថា លិខិតបញ្ជាក់លេខ ០៤៣ ប ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ នេះ មានខ្លឹមសារគ្រប់គ្រាន់សម្រាប់ឲ្យគណបក្ស ភ្លើងទៀន យកទៅប្រើប្រាស់ស្របតាមច្បាប់ជាធរមាន។

១១-នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣ គណបក្ស ភ្លើងទៀន បានផ្តល់ជូនគណៈកម្មាធិការជាតិរៀបចំ ការបោះឆ្នោត នូវឯកសារគ្រប់គ្រាន់ បំពេញបន្ថែមចំណុចខ្វះខាតនៃពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ របស់គណបក្ស ភ្លើងទៀន ពាក់ព័ន្ធភាពស្របច្បាប់របស់គណបក្ស ភ្លើងទៀន ដែលក្រសួងមហាផ្ទៃបានទទួលស្គាល់តាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ ក្នុងនោះមាន៖

- ប្រកាសលេខ ១៩៣ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ (ច្បាប់ថតចម្លង)។
- លិខិតលេខ ២០២៤ សជណ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការប្តូរឈ្មោះពី **គណបក្ស សម រង្ស៊ី** មកជា **គណបក្ស ភ្លើងទៀន** (ច្បាប់ថតចម្លងមានបញ្ជាក់នីត្យានុកូលកម្ម)។
- លិខិតលេខ ០៤៣ ប ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ដែលបញ្ជាក់ថា គណបក្ស ភ្លើងទៀន បានចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ដែលមានលោក ទាវ វណ្ណុល ជាប្រធានគណបក្ស និងមានអាសយដ្ឋានទីស្នាក់ការកណ្តាលបច្ចុប្បន្នផ្ទះលេខ ៣២០អឺសេរ៉ូ ផ្លូវ ១០ម៉ែត្រថ្មី (បុរីពិភពថ្មី) ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ (ច្បាប់ថតចម្លងមានបញ្ជាក់នីត្យានុកូលកម្ម)។

១២-នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានចេញសេចក្តីសម្រេចលេខ ២៣៣ គ.ជ.ប. ស.ស.រ បដិសេធការចុះបញ្ជីគណបក្សនយោបាយ ឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣របស់គណបក្ស ភ្លើងទៀន ដែលមាន ២៥ (ម្ភៃប្រាំ) មណ្ឌលរាជធានី ខេត្ត ដោយ គ.ជ.ប នៅតែសំអាងថា គណបក្ស ភ្លើងទៀន មិនបានភ្ជាប់មកជាមួយនូវប្រកាសលេខ ១៩៣ ប្រក ដែលមានបញ្ជាក់នីត្យានុកូលកម្ម ដដែល ដោយពុំទទួលស្គាល់លិខិតបញ្ជាក់លេខ ០៤៣ ប ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ នោះឡើយ។

១៣-នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ គណបក្ស ភ្លើងទៀន បានដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ប្តឹងតវ៉ានឹងសេចក្តីសម្រេចលេខ ២៣៣ គ.ជ.ប ស.ស.រ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងទាមទារឲ្យ គ.ជ.ប ទទួលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ របស់គណបក្ស ភ្លើងទៀន ដែលមាន ២៥ (ម្ភៃប្រាំ) មណ្ឌលរាជធានី ខេត្ត។

១៤-នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ មេធាវីតំណាងគណបក្ស ភ្លើងទៀន បានដាក់សារណាការពារ ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ អំពីអង្គហេតុ អង្គច្បាប់ (ទម្រង់ និងគតិច្បាប់) សេចក្តីសន្និដ្ឋាន និងសំណូមពរ ដើម្បីក្រុមប្រឹក្សាធម្មនុញ្ញ មានមូលដ្ឋានក្នុងការពិនិត្យ និងសម្រេចលើពាក្យបណ្តឹងតវ៉ារបស់គណបក្ស ភ្លើងទៀន ដែលប្តឹងតវ៉ាសេចក្តីសម្រេចលេខ ២៣៣ គ.ជ.ប ស.ស.រ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០២៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។

១៥-នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ ក្រុមប្រឹក្សាធម្មនុញ្ញ បានបើកកិច្ចប្រជុំពេញអង្គ សម្រេចបដិសេធពាក្យបណ្តឹងតវ៉ារបស់គណបក្ស ភ្លើងទៀន ដោយពុំមានការអញ្ជើញតំណាងគណបក្ស ភ្លើងទៀន ឬ មេធាវីគណបក្ស ចូលរួម និងពុំបានបើកសវនាការវិនិច្ឆ័យលើបណ្តឹងតវ៉ារបស់គណបក្ស ភ្លើងទៀន ជាចំហ (សាធារណៈ) ឡើយ។

សកម្មភាពការងារដែលបានរៀបរាប់ទាំងប៉ុន្មានខាងលើនេះ សរបញ្ជាក់ឲ្យឃើញថា **គណបក្ស ភ្លើងទៀន** បានខិតខំប្រឹងប្រែងតាមគ្រប់មធ្យោបាយ និងអស់ពីលទ្ធភាព ដើម្បីបានចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ផ្ទុយពីការចោទប្រកាន់ទាំងឡាយ ដែលថាគណបក្ស ភ្លើងទៀន ពុំមានឆន្ទៈពិតប្រាកដក្នុងការចូលរួមការបោះឆ្នោត ហើយមានឧបាយកលធ្វើឲ្យបរទេសដាក់ការគាបសង្កត់លើរាជរដ្ឋាភិបាល ឬបង្កចលាចលនៅក្នុងប្រទេសកម្ពុជា។

ជាថ្មីម្តងទៀត **គណបក្ស ភ្លើងទៀន** សូមប្រកាសជាឱឡារិក ជូនសាធារណជន ជាតិ និងអន្តរជាតិ ថា គណបក្ស នៅតែរក្សាជំហរ និងឆន្ទៈយ៉ាងមុតមាំក្នុងការចូលរួមការបោះឆ្នោត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងត្រៀមខ្លួនក្នុងការចូលរួមការបោះឆ្នោតជាបន្តបន្ទាប់នៅពេលខាងមុខ ដើម្បីផ្តល់ឱកាសដល់ប្រជាពលរដ្ឋក្នុងការសម្រេចចិត្តជ្រើសរើសតំណាងស្របតាមឆន្ទៈរបស់ខ្លួន ព្រមទាំងជម្រុញ និងលើកស្ទួយគ្រឹះលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅក្នុងប្រទេសកម្ពុជា៕

**ថ្ងៃអង្គារ ១១កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧**

**រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣**

**គណបក្ស ភ្លើងទៀន**

ព័ត៌មានបន្ថែម សូមទាក់ទង :

- ០៧៨ ៤៤ ៦៥ ៨៨